ព្រះរាជាណាចក្រកម្ពុជា

តុលាការកំពូល　　　　ជាតិ សាសនា ព្រះមហាក្សត្រ

សំណុំរឿងព្រហ្មទណ្ឌ　　　　**នាមនាមប្រជារាស្ត្រខ្មែរ**

លេខ : ៩១　　　　**តុលាការកំពូល**

ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០០៥

សាលដីកា　　　　បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី ១២ ខែ មេសា

លេខ : ៣៣　　　　ឆ្នាំ ២០០៦ ដោយមានសមាសភាពក្រុមប្រឹក្សាជំនុំជំរះដូចតទៅ :

ចុះថ្ងៃទី១២ ខែមេសា ឆ្នាំ២០០៦

| | | |
|---|---|---|
| ១- ឯកឧត្តម | **ឃឹម ប៉ុណ្ណ** | ប្រធាន |
| ២- លោក | ឈឹម ស៊ីផល | ចៅក្រម |
| ៣- លោក | វៀល មួន | ចៅក្រម |
| ៤- លោក | ស៊ិន ឌឹម | ចៅក្រម |
| ៥- លោក | យស់ សូខឿន | ចៅក្រម |
| ៦- លោក | សោម សិរីវឌ្ឍ | ចៅក្រម |
| ៧- លោក | ម៉ុង មុន្នីចរិយា | ចៅក្រម |
| ៨- លោក | យូរ ឧត្តរ៉ា | ចៅក្រម |
| ៩- លោក | ប៉ែន សាវឿន | ចៅក្រម-របាយការណ៍ |

ក្រឡាបញ្ជី

លោក សាន សុជាត

តំណាងមហាអយ្យការ

ឯកឧត្តម **ជួន ស៊ុនឡេង** អគ្គព្រះរាជអាជ្ញារង

ដើម្បីជំនុំជំរះលើបណ្តឹងលើកទី២ ពីសាលដីកាព្រហ្មទណ្ឌលេខ៦១"ង" ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០០៤ របស់សាលាឧទ្ធរណ៍ និង សំណុំរឿងព្រហ្មទណ្ឌលេខ៩១ ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០០៥ របស់តុលាការកំពូល ។

**ពីបទ** : បង្ករបួសស្នាមដោយចេតនា ប្រព្រឹត្តនៅភូមិថ្មី ឃុំកំពង់ប្រណាក ស្រុកត្បែងមានជ័យ ខេត្តព្រះវិហារ កាលពីថ្ងៃទី០១ ខែមិថុនា ឆ្នាំ១៩៩៧តាមបញ្ញត្តិមាត្រា៤១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

-ជនជាប់ចោទឈ្មោះ លាង គីមយិន "ជាម្ចាស់បណ្តឹងសាទុក្ខ" ភេទស្រី អាយុ៣០ឆ្នាំ ជាតិខ្មែរ កើតនៅភូមិក្តី ឃុំក្តីដូង ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ របររកស៊ីលក់ដូរ ទីលំនៅសព្វថ្ងៃភូមិថ្មី ឃុំកំពង់-ប្រណាក ស្រុកត្បែងមានជ័យ ខេត្តព្រះវិហារ ឪពុកឈ្មោះលាង ទ្រី ម្តាយឈ្មោះហ៊ុន សុះ ប្តីឈ្មោះស៊ឹម រិត មាន០៤នាក់ ។ ក្រៅឃុំ ។

-មានមេធាវី លោក សែម ចិន្តា

-ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះឡុញ សុផុន "ជាចុងបណ្ដឹងសាទុក្ខ" ភេទប្រុស អាយុ៣៨ឆ្នាំ ជាតិខ្មែរ មុខរបរបើកបររថយន្ត ទីលំនៅសព្វថ្ងៃភូមិអណ្ដូងពោធិ ឃុំកំពង់ប្រណាក ស្រុកត្បែងមានជ័យ ខេត្តព្រះវិហារ ។

-មានមេធាវី លោក ជេង ស៊ីដេត

-តាមពាក្យបណ្ដឹង ចុះថ្ងៃទី១០-៩-១៩៩៧ របស់ឈ្មោះឡុញ សុផុន ហៅ ហេង ម៉ៅ ប្ដឹងពីឈ្មោះលាង គឹមយិន បានយកកំណាត់ឈើវាយខ្លួនបណ្ដាលឱ្យរបួសជាទម្ងន់នៅត្រង់ចុងចិញ្ចើមខាងឆ្វេង កាលពីថ្ងៃទី០១ ខែសីហា ឆ្នាំ១៩៩៧ ក្នុងរឿងនេះខ្លួនសុំប្ដឹងឱ្យឈ្មោះលាង គឹមយិន បង់ថ្លៃព្យាបាលរបួស ថ្លៃការខូចខាតក្នុងមុខរបរ និងជម្ងឺចិត្តសរុបទាំងអស់៦.០០០.០០០ (ប្រាំមួយលានរៀល) ចំណែកជនល្មើសសុំឱ្យតុលាការផ្ដន្ទាទោសតាមច្បាប់ ។

-បានឃើញសេចក្ដីសន្និដ្ឋានរបស់តំណាងអយ្យការ អមតុលាការខេត្តព្រះវិហារថា : ចោទប្រកាន់លើឈ្មោះលាង គឹមយិន ភេទស្រី អាយុ៣០ឆ្នាំ ជាតិខ្មែរ ស្រុកកំណើត ភូមិក្ដី ឃុំក្ដីដូង ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ សព្វថ្ងៃនៅភូមិថ្មី ឃុំកំពង់ប្រណាក ស្រុកត្បែងមានជ័យ ខេត្តព្រះវិហារ ពីបទ:បង្ករបួសស្នាមដោយចេតនា កាលពីថ្ងៃទី០១ ខែសីហា ឆ្នាំ១៩៩៧ បទល្មើសដែល មានចែងឱ្យផ្ដន្ទាទោសតាមមាត្រា៤១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

-បានឃើញសាលក្រមព្រហ្មទណ្ឌលេខ០៧ ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ១៩៩៧ របស់តុលាការខេត្តព្រះវិហារ ដែលបានសំរេច :

១-ផ្ដន្ទាទោសជនជាប់ចោទឈ្មោះលាង គឹមយិន ដាក់ពន្ធនាគារកំណត់៦ខែ គិតពីថ្ងៃប្រកាសសាលក្រមនេះតទៅ តែទោសនេះត្រូវព្យួរកំណត់រយៈពេលសាកល្បង០១ឆ្នាំ ពីបទ : បង្ករបួសស្នាមដោយចេតនា ប្រព្រឹត្តនៅភូមិថ្មី ឃុំកំពង់ប្រណាក ស្រុកត្បែងមានជ័យ ខេត្តព្រះវិហារ កាលពីថ្ងៃទី០១ ខែសីហា ឆ្នាំ១៩៩៧ តាមមាត្រា៤១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

២-វត្ថុតាងប្រភេទឈើទំហំ០,៣៥m×០,៩៥cm ប្រវែង០,៥០ម និងទំងន់១,៥kg ត្រូវរឹបអូសរួចបំផ្លាញចោល ។

៣-បង្គាប់ឱ្យឈ្មោះលាង គឹមយិន បង់ប្រាក់ថ្លៃព្យាបាលរបួស ប្រាក់ជម្ងឺចិត្ត និងប្រាក់ថ្លៃការខាតបង់ក្នុងមុខរបរទៅឱ្យឈ្មោះឡុញ សុផុន ហៅ ហេង ម៉ៅ សរុបចំនួន៣.០០០.០០០រៀល(បីលានរៀល) ការទាមទារលើសពីនេះបដិសេធចោល ។ ក្នុងករណីមិនបង់ បង្គាប់ឱ្យដាក់គុកបង្ខំដល់រូបកាយដល់ឈ្មោះលាង គឹមយិន ដើម្បីទារប្រាក់ធនទណ្ឌតាមមាត្រា៧ នៃច្បាប់ស្ដីពីការដាក់គុកបង្ខំដល់រូបកាយក្នុងរឿងព្រហ្មទណ្ឌ ។

សាលក្រមនេះជំនុំជំរះជាសាធារណៈ ចំពោះមុខគូក្ដី បើកផ្លូវឧទ្ធរណ៍ក្នុងកំណត់ច្បាប់ គិតពីថ្ងៃប្រកាសសាលក្រមនេះតទៅ ។

-បានឃើញបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ១៩៩៧ របស់ឈ្មោះ លាង គីមយិន ប្តឹងមិនសុខចិត្តពីសាលក្រមព្រហ្មទណ្ឌលេខ០៧ ចុះថ្ងៃទី២០-១០-១៩៩៧ របស់តុលាការខេត្តព្រះវិហារ លើសេចក្តីសំរេចទាំងមូល ។

-បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ អមសាលាឧទ្ធរណ៍ ថា :

១-ទទួលពាក្យបណ្តឹងឧទ្ធរណ៍របស់ឈ្មោះលាង គីមយិន ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែត្រូវបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ០៧ ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ១៩៩៧ ត្រង់ចំណុចទីបីទុកជាបានការតទៅ ប៉ុន្តែត្រូវកែប្រែចំណុចទី១ ត្រង់រយៈពេលសាកល្បងតាមមាត្រា៧០ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាលឡើងវិញ ដើម្បីជាផលប្រយោជន៍ច្បាប់ ។

-បានឃើញសាលដីកាព្រហ្មទណ្ឌលេខ៩៧ ចុះថ្ងៃទី០៥ ខែមេសា ឆ្នាំ២០០០ របស់សាលាឧទ្ធរណ៍ ដែលបានសំរេច :

១-ទទួលពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី១១-១១-១៩៩៧ របស់ឈ្មោះលាង គីមយិន ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ។

២-តំកល់សាលក្រមព្រហ្មទណ្ឌលេខ០៧ ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ១៩៩៧របស់តុលាការខេត្តព្រះវិហារ ទុកជាបានការដដែល ដោយគ្រាន់តែកែប្រែរយៈពេលសាកល្បងក្នុងចំណុចទី១ នៃសេចក្តីសំរេចពី១ឆ្នាំមកជ៥ឆ្នាំវិញ តាមមាត្រាទី៧០ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល និងកែប្រែសំណងថ្លៃថ្នាំព្យាបាល និងជម្ងឺចិត្តក្នុងចំណុចទី៣ នៃសេចក្តីសំរេចពី៣.០០០.០០០ (បីលានរៀល) មក ២.០០០.០០០រៀល (ពីរលានរៀល) វិញ ចំណុចក្រៅពីនេះទុកជាបានការដដែល ។

៣-សាលដីកានេះជំនុំជំរះ និង ប្រកាសជាសាធារណៈចំពោះមុខជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណី បើកផ្លូវប្តឹងសាទុក្ខតាមកំណត់ច្បាប់ ។

-បានឃើញបណ្តឹងសាទុក្ខលេខ៣៥ ចុះថ្ងៃទី០៥ ខែមេសា ឆ្នាំ២០០០ របស់ឈ្មោះលាង គីមយិន ដែលប្តឹងមិនសុខចិត្តពីសាលដីកាព្រហ្មទណ្ឌលេខ៩៧ ចុះថ្ងៃទី០៥ ខែមេសា ឆ្នាំ២០០០ របស់សាលាឧទ្ធរណ៍ លើសេចក្តីសំរេចទាំងមូល ។

-បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ អមតុលាការកំពូល ថា : ក្នុងរឿងនេះពិនិត្យឃើញថា តុលាការថ្នាក់ក្រោមពុំបានសួរសាក្សីរបស់ជនជាប់ចោទនៅឡើយ ដូច្នោះពុំអាចដាក់បន្ទុកបានទេ សូមបដិសេធសាលដីកាសាលាឧទ្ធរណ៍ ។

-បានឃើញសាលដីកាព្រហ្មទណ្ឌលេខ១៧ ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០០២ របស់តុលាការកំពូល ដែលបានសំរេច :

១-ទទួលបណ្តឹងសាទុក្ខលេខ៣៥ ចុះថ្ងៃទី០៥ ខែមេសា ឆ្នាំ២០០០ របស់ឈ្មោះលាង គីមយិន ទុកជាត្រឹមត្រូវតាមទំរង់ និងគតិច្បាប់ ។

២-ទុកជាមោឃៈសាលដីកាព្រហ្មទណ្ឌលេខ៩៧ ចុះថ្ងៃទី០៥ ខែមេសា ឆ្នាំ២០០០ របស់សាលាឧទ្ធរណ៍ទាំងមូល ។

៣-បង្វិលសំណុំរឿងព្រហ្មទណ្ឌលេខ២៨ ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០០១ របស់តុលាការកំពូលទៅសាលាឧទ្ធរណ៍ ដើម្បីជំនុំជំរះជាថ្មីឡើងវិញ ។

៤-សាលដីកានេះប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០០២ ។

-បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ អមសាលាឧទ្ធរណ៍ ថា : មានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះលាង គីមយិន ។ ដូច្នោះគួរបដិសេធសាលក្រមតុលាការខេត្ត និងសំរេចផ្តន្ទាទោសជន ល្មើសតាមច្បាប់ ចំពោះសំណងសំរេចលើក្រុមប្រឹក្សា ។

-បានឃើញសាលដីកាព្រហ្មទណ្ឌលេខ៦១"ង" ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០០៤ របស់សាលាឧទ្ធរណ៍ ដែលបានសំរេច :

១-ទទួលជំនុំជំរះសំណុំរឿងក្តីព្រហ្មទណ្ឌលេខ២៦៧ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ តាមសាលដីកាព្រហ្មទណ្ឌលេខ១៧ ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០០២ របស់តុលាការកំពូល ។

២-ផ្តន្ទាទោសឈ្មោះលាង គីមយិន ភេទស្រី អាយុ៣០ឆ្នាំ កើតនៅភូមិក្តី ឃុំក្តីដូង ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ មានទីលំនៅសព្វថ្ងៃភូមិថ្មី ឃុំកំពង់ប្រណាក ស្រុកត្បែងមានជ័យ ខេត្តព្រះវិហារ ដាក់ពន្ធនាគារកំណត់០៦ខែ (ប្រាំមួយខែ) តែទោសនេះត្រូវព្យួរដោយកំណត់រយៈពេលសាកល្បង៥ឆ្នាំ ចាប់គិតពីថ្ងៃដែលសាលដីកានេះចូលជាស្ថាពរ ពីបទបង្ករបួសស្នាមដោយចេតនាមានអាវុធ ប្រព្រឹត្តកាលពីថ្ងៃទី០១ ខែសីហា ឆ្នាំ១៩៩៧ នៅភូមិថ្មី ឃុំកំពង់ប្រណាក ស្រុកត្បែងមានជ័យ ខេត្តព្រះវិហារ តាមមាត្រា៤១ ច្បាប់ព្រហ្មទណ្ឌអន្តរកាល ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ១៩៩២ ។

៣-បង្គាប់អោយឈ្មោះលាង គីមយិន បង់ប្រាក់ថ្លៃថ្នាំព្យាបាលជម្ងឺចិត្តសរុបចំនួន៣លានរៀល ទៅឱ្យឈ្មោះឡុញ សុផុន ហៅ ហេង ម៉ៅ នៅពេលដែលសាលដីកានេះចូលជាស្ថាពរ ។ សំណូមពរលើសពីនេះបដិសេធចោល ។

៤-ក្នុងករណីឈ្មោះលាង គីមយិន គ្មានប្រាក់សង ឬរឹងរូសអនុញ្ញាតិឱ្យដាក់គុកបង្ខំលើរូបកាយលើឈ្មោះនេះ តាមមាត្រា៧នៃច្បាប់ស្តីពីការដាក់គុកបង្ខំលើរូបកាយក្នុងរឿងព្រហ្មទណ្ឌ ។

៥-វត្ថុតាងឈើទំហំ០,៣៥cm×០,៩៥cm ប្រវែង០,៥០m ត្រូវរឹបអូសនិងបំផ្លាញចោល ។

៦-សាលដីកានេះជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណី កំបាំងមុខជនជាប់ចោទ ។ បើកផ្លូវប្តឹងតវ៉ាតាមកំណត់ច្បាប់ ។

-បានឃើញបណ្តឹងសាទុកលើកទី២លេខ១៣៥ ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០០៤ របស់ឈ្មោះលាង គីមយិន ប្តឹងមិនសុខចិត្តពីសាលដីកាព្រហ្មទណ្ឌលេខ៦១"ង" ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០០៤ របស់សាលាឧទ្ធរណ៍ លើសេចក្តីសំរេចទាំងមូល ។

-បានឃើញសារណា ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០០៥ របស់ឈ្មោះលាង គឹមយិន ( ជាម្ចាស់បណ្តឹងសាទុក្ខ) ធ្វើឡើងតាមកំណត់ច្បាប់ ។

-បានឃើញសារណាតប ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០០៥ របស់ឈ្មោះឡុញ សុផុន "ជាចុងបណ្តឹងសាទុក្ខ" ធ្វើឡើងតាមកំណត់ច្បាប់ ។

- បានស្តាប់ចៅក្រមរបាយការណ៍ អានរបាយការណ៍

- បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ អមតុលាការកំពូលថា : រឿងនេះមានភស្តុតាងគ្រប់គ្រាន់ហើយ។សាលាឧទ្ធរណ៍សំរេចសេចក្តីមកនេះមានលក្ខណៈត្រឹមត្រូវ សូមក្រុមប្រឹក្សាជំនុំជំរះមេត្តាពិនិត្យ និងសំរេច ។

-បានស្តាប់ចម្លើយអះអាងរបស់ជនជាប់ចោទឈ្មោះលាង គឹមយិន "ជាម្ចាស់បណ្តឹងសាទុក្ខ" នៅពេលជំនុំជំរះថា : ឈ្មោះឡុញ សុផុន ២នាក់ប្តីប្រពន្ធវាយនាងខ្ញុំមិនមែនក្រោយពេលកើតហេតុ ឡុញ សុផុន ទើបតែមកដល់ទេ គឺ ឡុញ សុផុន នៅកន្លែងកើតហេតុរហូត រឿងនេះដំបូងជេរទៅជេរមក ទើបបណ្តាលឱ្យមានរឿងបែបនេះ ។ សូមឱ្យតុលាការចោទប្រកាន់ ឡុញ សុផុន ផង និងសូមលើកលែងចោទប្រកាន់នាងខ្ញុំដោយក្តីអនុគ្រោះ ។

-បានស្តាប់ចម្លើយអះអាងរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះឡុញ សុផុន "ជាចុងបណ្តឹងសាទុក្ខ" នៅពេលជំនុំជំរះថា : នៅពេលឈ្មោះគ្នាបន្តិច ទើបខ្ញុំបាទទៅដល់ជួយចាប់ឃាត់គ្នាចេញ ។ ឈ្មោះលាង គឹមយិន យកឈើវាយខ្ញុំ។ឈប់ពុំដឹងខ្លួន ដឹងខ្លួនស្រាប់នៅក្នុងមន្ទីរពេទ្យ ក្នុងរឿងនេះខ្ញុំប្តឹងទាមទារសំណងជំងឺចិត្តបន្ថែមចំនួន៦លានរៀល និងផ្តន្ទាទោសជនជាប់ចោទតាមច្បាប់ ។

-បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោកសែម ចិន្តា មេធាវីការពារឱ្យជនជាប់ចោទឈ្មោះលាង គឹមយិន "ជាម្ចាស់បណ្តឹងសាទុក្ខ" នៅពេលជំនុំជំរះថា : មានសាក្សីឈ្មោះឡើង បានឆ្លើយថា រឿងនេះមានការវាយទៅវាយមក ឈ្មោះឡុញ សុផុន ខ្លួនឯងក៏បានឆ្លើយនៅក្នុងកំណត់ហេតុតុលាការថ្នាក់ក្រោមដែរ ។ បើពីនាក់ប្តីប្រពន្ធមិនមកទារលុយពីកូនក្តីខ្ញុំ ក៏មិនមានរឿងទេ តុលាការថ្នាក់ក្រោមសំរេចខ្វះចន្លោះ សូមតុលាការសំរេចចោទប្រកាន់ឈ្មោះឡុញ សុផុន ទៅតាមច្បាប់ ។

-បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោកជេង ស៊ីដេត មេធាវីការពារឱ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះឡុញ សុផុន "ជាចុងបណ្តឹងសាទុក្ខ" នៅពេលជំនុំជំរះថា : មានសាក្សីបញ្ជាក់ថា កូនក្តីខ្ញុំបាទពុំនៅកន្លែងកើតហេតុទេ វត្ថុតាង និងសាក្សីស៊ីចង្វាក់គ្នា កូនក្តីខ្ញុំមានសំបុត្រពេទ្យត្រឹមត្រូវ សូមតុលាការតម្កល់សាលដីកាសាលាឧទ្ធរណ៍ទុកជាបានការ ។

-បានស្តាប់សេចក្តីសន្និដ្ឋានបន្ថែមរបស់តំណាងមហាអយ្យការ អមតុលាការកំពូល ថា : គ្មានយោបល់អ្វីបន្ថែម ទៀតទេ ។

-ក្រោយពីបានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់ចម្លើយដោះសាររបស់ជនជាប់ចោទ ដើមបណ្តឹងរដ្ឋប្បវេណី និងសេចក្តីសន្និ-

ដ្ឋានរបស់មេធាវីជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណី ។

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ ។

## តុលាការកំពូល

-យល់ឃើញថា បណ្តឹងសាទុក្ខលើកទី២លេខ១៣៥ ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០០៤ របស់ឈ្មោះ លាង គឹមឃិន ធ្វើឡើងស្ថិតក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះ មកជំនុំជំរះបានតាម មាត្រា ១៤ នៃច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់ សាលាជំរះក្តី និង មាត្រា២២៦ នៃច្បាប់ស្តីពី នីតិវិធីព្រហ្មទណ្ឌ ។

-យល់ឃើញថា សាលាឧទ្ធរណ៍បានសំរេចបដិសេធចោលជាអស្សារបង់សាលក្រមលេខ០៧ ចុះថ្ងៃ ទី២០ ខែតុលា ឆ្នាំ១៩៩៧ ដែលសំរេចដោយខុសនីតិវិធីរួចហើយ ប៉ុន្តែសាលាឧទ្ធរណ៍ក៏ពុំបានចាត់ការធ្វើ ការស៊ើបអង្កេតដោយខ្លួនឯង ដូចការកំណត់នៃមាត្រា១៩២ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌនោះទេ ដោយ ពេលនេះតុលាការកំពូលត្រូវសំរេចដល់អង្គសេចក្តីនោះ តុលាការកំពូលគប្បីចាត់របៀបធ្វើការស៊ើបអង្កេត ដោយខ្លួនឯងអោយបានច្បាស់លាស់ ។

## ហេតុដូច្នេះ

**សំរេចសេចក្តីចំពោះមុខជនជាប់ចោទ និង ដើមបណ្តឹងរដ្ឋប្បវេណី ៖**

១-ចាត់របៀបឱ្យចៅក្រមតុលាការកំពូល ធ្វើការស៊ើបអង្កេតនូវរឿងក្តីនេះជាថ្មីឡើងវិញ ។

២-សាលដីកានេះប្រកាសនាសវនាការ ជាសាធារណៈ នៅថ្ងៃទី១២ ខែមេសា ឆ្នាំ២០០៦ ។